**Declassified to Public**
**06 September 2012**

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

---

## ការបើកកិច្ចស៊ើបអង្កេតរបស់តុលាការចំពោះ កាំង ហ្គេច អ៊ាវ (ហៅ "ឌុច") បណ្តឹងឧទ្ធរណ៍របស់មេធាវីទៅអង្គបុរេជំនុំជម្រះ

---

## សារណារបស់លោក STAN STARYGIN *ជាមិនមែនជាភាគីនៃរឿងក្តី ដើម្បីជួយគាំទ្រដល់ជនជាប់ឃុំ(Detainee)*[១]

## **ចំណាប់អារម្មណ៍នៃតតិយជនឯកទេសក្នុងរឿងក្តី**[២] Interest of the Amicus Curiae

---

[១] ខ្ញុំបានជ្រើសយកការប្រើពាក្យ "ជនជាប់ឃុំ (detainee)"នៅទីនេះ ដោយសារ ពិបាកក្នុងសម្របសម្រួលប្រព័ន្ធច្បាប់ស៊ីវិល ដែលបារាំងប្រើពាក្យ "personne mise en examen" ដែលមានន័យពិតប្រាកដគឺ "បុគ្គលឋិតក្រោមការស៊ើបអង្កេត" ហើយពាក្យពេចន៍ប្រព័ន្ធច្បាប់ Common law "arraigned និង indicted"។ ដីកាឃុំខ្លួន កាំង ហ្គេច អ៊ាវ បណ្តោះអាសន្ន ប្រើប្រាស់ពាក្យ "ជនត្រូវចោទ (Charged person)" "personne mise en examen" គឺមិនត្រឹមត្រូវទាំងស្រុងនោះទេនៅពេលគេនិយាយយោងដល់បុគ្គលម្នាក់ត្រូវ "ចោទ (charged)" ការចោទប្រកាន់គឺឋិតក្រោមកាតព្វកិច្ចមួយដែលត្រូវបកស្រាយឱ្យបានពិស្តារថែមទៀតអំពីការចោទប្រកាន់ទៅកាន់តុលាការជាជាងគ្រាន់តែចោទប្រកាន់ត្រឹមតែឈ្មោះដែលហាក់ដូចជាករណីមួយក្នុងប្រព័ន្ធច្បាប់ស៊ីវិល។ ជាងនេះទៅទៀត វានៅមិនច្បាស់ថាតើចៅក្រមស៊ើបអង្កេតនឹងអនុញ្ញាតឱ្យសំណុំរឿងនេះឈានទៅដល់ការជំនុំជម្រះឬទេ ហើយប្រសិនជាដូច្នោះមែននោះ តើឋិតនៅក្នុងទម្រង់ណា?។ ចំនុចនេះជាការគ្រប់គ្រងស្ថានភាពបុគ្គលបែបនេះក្រោមកម្រិតមួយនៃ "ជនជាប់ចោទ (accused) " ប៉ុន្តែលើកម្រិតមួយនៃ"ជនសង្ស័យ (suspect)" ហើយក៏ឋិតក្នុងកម្រិតមួយដែលជាធម្មតាពុំមាននៅក្នុងប្រព័ន្ធច្បាប់ Common law ទេ។ វាជាការពិតដែលថា កាំង ហ្គេច អ៊ាវ ត្រូវបាន អ.វ.ត.ក ឃុំខ្លួនដោយសារការផ្ទេរគាត់មកពីតុលាការយោធា ហើយក្រោយមកមានការចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ដូចបានពិភាក្សាខាងលើ។ ហេតុដូច្នេះ ការប្រើពាក្យ "ជនជាប់ឃុំ (detainee)" ហាក់ ដូចជាពាក្យពេចន៍មួយសាកសម្បជាង ក្នុងការពិពណ៌នាអំពីស្ថានភាពបច្ចុប្បន្នរបស់គាត់ ហើយក៏ជាពាក្យមួយហាក់ដូចជាសម្របសម្រួលដល់ភាសាបារាំងជាមួយនឹងភាសាអង់គ្លេសបានផងដែរ។

00154362

(ភាគីអព្យាក្រិត្យមួយ ដែលមិនមែនជាតំណាងឱ្យភាគីណាមួយក្នុងរឿងក្តី ហើយដែលតុលាការស្នើសុំឱ្យគាត់ធ្វើបទបង្ហាញអំពីទស្សនៈឯករាជរបស់គាត់)

*ភាគីអព្យាក្រិត្យក្នុងរឿងក្តី* គឺលោក Stan Starygin[៣] ដែលរយៈពេលជាងពីរបីឆ្នាំមុន គាត់បានសិក្សាស្រាវជ្រាវអំពីស្ថានភាពឃុំខ្លួន កាំង ហ្គេច អ៊ាវ ដោយប្រៀបធៀបច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ហើយគាត់បានពិនិត្យមើលការប្រមូលបានភស្តុតាងជាច្រើន ដើម្បីជួយគាំទ្រដល់ការចោទប្រកាន់ដែលបានធ្វើឡើងប្រឆាំងនឹង កាំង ហ្គេច អ៊ាវ ចាប់តាំងពីការចាប់ខ្លួននៅឆ្នាំ១៩៩៩។ *ភាគីអព្យាក្រិត្យក្នុងរឿងក្តី* បានដឹកនាំការស្រាវជ្រាវច្បាប់ជាច្រើនអំពីបញ្ហាទាក់ទងនឹងនីតិវិធីនៃការធានាក្នុងតុលាការកម្ពុជា និងការបង្កើតលក្ខន្តិកៈ នៅកម្រិតជាតិ និងអន្តរជាតិ។ នៅក្នុងសារណានេះ *ភាគីអព្យាក្រិត្យក្នុងរឿងក្តី* នឹងបង្ហាញពីការពិនិត្យមើលអង្គច្បាប់ក្នុងតុលាការកម្ពុជា និងបង្ហាញពីការជជែកវែកញែកពីទំនាក់ទំនងរបស់ អ.វ.ត.ក ជាមួយនឹងយុត្តាធិការតុលាការក្នុងស្រុកធម្មតារបស់កម្ពុជា។ *ភាគីអព្យាក្រិត្យក្នុងរឿងក្តី* នឹងបង្ហាញអំពីលទ្ធផលនៃការជជែកវែកញែកនេះអាចជះ

---

[២] ពុំមានការស្វែងរកការយល់ព្រមពីភាគីនានាចំពោះកិច្ចដំណើរការនីតិវិធីទាំងនេះ មុនការរៀបចំចងក្រងឯកសារនេះឡើយ។ សារណាភាគីអព្យាក្រិត្យក្នុងរឿងក្តី ត្រូវបានរៀបចំចងក្រងឡើងផ្ទាល់ ដើម្បីឆ្លើយតបទៅនឹងការស្នើសុំរបស់អង្គបុរេជំនុំជម្រះរបស់អ.វ.ត.ក នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៧ ដែលប្រើប្រាស់អំណាចអង្គបុរេជំនុំជម្រះ ក្រោមវិធាន៣៣នៃ វិធានផ្ទៃក្នុងរបស់អ.វ.ត.ក។

[៣] លោក Stan Starygin គឺជាសាស្ត្រាចារ្យច្បាប់និងទំនាក់ទំនងអន្តរជាតិមួយរូប។ គាត់បានផ្សព្វផ្សាយយ៉ាងច្រើនអំពីបញ្ហានានាទាក់ទងនឹងការកែទម្រង់ច្បាប់ និងតុលាការកម្ពុជា ជាពិសេស ការផ្សព្វផ្សាយរបស់គាត់ផ្តោតអំពីការធានាពីនីតិវិធីនៃជនជាប់ចោទ និងភាគីប្តឹងឧទ្ធរណ៍ដែលជាប់ឃុំ។ គាត់បានធ្វើបទសម្ភាសន៍ជនជាតិកម្ពុជាមួយចំនួនធំ ដែលបានរស់នៅឆ្លងកាត់អំឡុងពេលនៃការកើតឡើងនៃរបបខ្មែរក្រហម(ចុងទសវត្សរ៍ទី៦០ ដល់ឆ្នាំ១៩៧៥) និងការគ្រប់គ្រងអំណាចរបស់ក្រុមនេះដែលមានឈ្មោះថា"កម្ពុជាប្រជាធិបតេយ្យ" "១៩៧៥-១៩៧៩" និងបានធ្វើសម្ភាសន៍ជនទាំងឡាយ ដែលបានបន្តរស់នៅក្រោមពួកខ្មែរក្រហម ដែលក្រោយមកពួកនេះបានក្លាយជាផ្នែកមួយនៃរដ្ឋាភិបាលចំរុះកម្ពុជាប្រជាធិបតេយ្យ។ គាត់មានចំណាប់អារម្មណ៍ពិសេសទៅលើប្រតិបត្តិការមន្ទីរសន្តិសុខក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់បុគ្គលជាប់ឃុំរូបនេះ។ គាត់បានសិក្សាអំពីជីវិតរបស់ជនជាប់ឃុំរូបនេះ មុននិងក្រោយការកាន់តួនាទីជាប្រធាន សន្តិសុខក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានសិក្សាយ៉ាងច្រើនពីច្បាប់កម្ពុជា និងច្បាប់អន្តរជាតិដែលមានស្រាប់ ដូចបានអនុវត្តចំពោះករណីជនជាប់ឃុំរូបនេះ។ ការងារនេះបាននាំឱ្យមានការពិនិត្យឡើងវិញនូវច្បាប់មួយចំនួននិងអត្ថបទផ្សាយជាច្រើន។ លោកអ្នកអាចទាក់ទង *ភាគីអព្យាក្រិត្យក្នុងរឿងក្តី* ដើម្បីសាកសួរព័ត៌មានបន្ថែម តាមរយៈ អាស័យដ្ឋានអ៊ីម៉ែល stan.starygin@gmail.com

ឥទ្ធិពលដល់ស្ថានភាពឃុំខ្លួន បណ្តោះអាសន្នបច្ចុប្បន្ន (ស្ថានភាពឃុំខ្លួនមុនការជំនុំជម្រះ) របស់ជនជាប់ឃុំ និងការឃុំខ្លួនមុនការជំនុំជម្រះនៅកម្ពុជាជាទូទៅ។

## របាយការណ៍នៃសំណុំរឿង

ការស៊ើបអង្កេតពីបទឧក្រិដ្ឋមួយទៅលើ កាំង ហ្គេច អ៊ាវ ហៅ(ឌុច) ត្រូវបានបើកធ្វើឡើងនៅថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩៩ (សំណុំរឿងលេខ ៣៩៧) ការស៊ើបអង្កេតនោះបាននាំឱ្យមានការចាប់ខ្លួនជនសង្ស័យនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៩។ ក្រោយមក គេបានដកស្រង់សំដីអាជ្ញាធរចាប់ខ្លួនដោយនិយាយថា "អាចមានការចោទប្រកាន់តាមក្រោយ"[៤]។ នេះគឺជាការអនុវត្តដីកាបញ្ជូនរឿងឱ្យស៊ើបអង្កេត (លេខ០២៩/៩៩)ចុះនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ចោទប្រកាន់ កាំង ហ្គេច អ៊ាវ ដោយការកំណត់អត្តសញ្ញាណគាត់ថាជា "ប្រធានមន្ទីរសន្តិសុខគុកទួលស្លែង" ហើយចោទប្រកាន់ពី "បទឧក្រិដ្ឋប្រឆាំងនឹងសន្តិសុខក្នុងស្រុក ជាមួយនឹងចេតនាបំរើឱ្យគោលនយោបាយក្រុមកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តឡើងក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" ។ មាត្រា២ មាត្រា៣ និង៤នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ (ឆ្នាំ១៩៩៤) និងមាត្រា៧ នៃ Decree Law 2 (១៩៨០)[៥] ត្រូវបានគេពិពណ៌នាថា ជាមូលហេតុសំរាប់ធ្វើការចោទប្រកាន់។ ចៅក្រមស៊ើបអង្កេតតុលាការយោធាក្រុងភ្នំពេញ បានឆ្លើយតបទៅនឹងដីកាបញ្ជូនរឿងឱ្យស៊ើបអង្កេត តាមរយៈដីកាមួយឱ្យមានការស៊ើបអង្កេតបន្ថែម (លេខ១៤០) នៅថ្ងៃដដែល (ថ្ងៃទី១០ ខែឧសភា ឆ្នាំ ១៩៩៩)។ ចៅក្រមស៊ើបអង្កេតបានចេញដីកាមួយផ្សេងទៀតដើម្បីឃុំខ្លួនបន្ថែមរយៈពេលបីខែបន្ទាប់ ពីការចេញដីកាលើកទីមួយ (ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩)។ មុនផុតរយៈពេលអតិបរមានៃការឃុំខ្លួនមុនការជំនុំជម្រះ ដែលអនុញ្ញាតដោយច្បាប់ មានច្បាប់ថ្មីមួយស្តីពីការឃុំខ្លួនបណ្តោះអាសន្ន/ការឃុំខ្លួនមុនការជំនុំជម្រះ ត្រូវបានអនុម័តនៅ(ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩)

---

[៤] World: Asia Pacific មន្ត្រីសហប្រជាជាតិជួបជាមួយឃាតករខ្មែរក្រហម, BBC News ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ មាននៅក្នុងវិបសាយ http://news.bbc.co.uk/1/hi/world /asia-pacific/340151.stm (បានទស្សនាចុងក្រោយថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧)។

[៥] Decree Law 2 ត្រូវបានចងក្រងជាច្បាប់ព្រហ្មទណ្ឌនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា របបមួយដែលមិនទាន់មានរវាងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឬនៅពេលដែល កាំង ហ្គេច អ៊ាវ មិនទាន់ត្រូវបានចាប់ខ្លួន។ នៅពេលចាប់ខ្លួន កាំង ហ្គេច អ៊ាវ Decree Law 2 ត្រូវបានជំនួសដោយ

ដែលបញ្ជាក់ជាថ្មីអំពីការចែងនៃមាត្រា១៤ ជា ខ បញ្ញត្តិ ដែលទាក់ទងនឹងតុលាការ និងច្បាប់និងនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តនៅកម្ពុជា ក្នុងអំឡុងពេលអន្តរកាល (ក្រោយមកហៅថា "ច្បាប់អ៊ុនតាក់" ច្បាប់នេះបានកំណត់អំពីការឃុំខ្លួនមុនការជំនុំជម្រះ រហូតដល់៤ខែ និងរយៈពេលច្រើនបំផុត៦ខែ ដោយបញ្ជាក់គំនិតសមហេតុសមផលរបស់ចៅក្រម ប៉ុន្តែច្បាប់នេះបានបន្ថែមប្រភេទសំខាន់ថ្មីមួយអំពីបទឧក្រិដ្ឋទាំងឡាយដូចជា (បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ដែលរយៈពេលនៃការឃុំខ្លួនមុនការជំនុំជម្រះត្រូវបានបន្ថែមរហូតដល់១ឆ្នាំ និងច្រើនបំផុត៣ឆ្នាំ។ ច្បាប់ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះថ្មីនេះ បានបង្កើតក្របខណ្ឌមួយ ដែលតុលាការយោធាក្រុងភ្នំពេញអាចចោទប្រកាន់ កាំង ហ្គេច អ៊ាវ ជាថ្មីរៀងរាល់បីឆ្នាំម្តង។ ហេតុដូច្នេះ កាំង ហ្គេច អ៊ាវ ត្រូវបាន (ចោទប្រកាន់ជាថ្មី) នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩ នៅជិតផុតរយៈពេល៤ខែចាប់តាំងពីគាត់ត្រូវបានចាប់ខ្លួនលើកដំបូង (ច្បាប់ថ្មីស្តីពីការឃុំខ្លួនមុនការជំនុំជម្រះនេះ មិនទាន់ត្រូវបានអនុវត្តចំពោះរឿងក្តីនេះនៅពេលដំបូងនេះទេ)។ ការចោទប្រកាន់លើកទីពីរ (ដីកាបញ្ជូនរឿងឱ្យស៊ើបអង្កេតលេខ០៤៤/៩៩) ពុំមានការពោលយោង ទៅលើការចោទប្រកាន់លើកទីមួយទេ ហើយគេបានប្រើ Decree Law 1[៦] ជាមូលដ្ឋានសំរាប់ធ្វើការចោទប្រកាន់ថ្មីមួយអំពីបទប្រល័យពូជសាសន៍។ ៥ខែក្រោយមក កាំង ហ្គេច អ៊ាវ ត្រូវបាន "ចោទប្រកាន់ជាថ្មី"ម្តងទៀត ផ្អែកលើមូលដ្ឋាននៃមាត្រា៥ និង៣៩នៃច្បាប់ ដែលទើបត្រូវបានអនុម័តរួចថ្មីៗ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មដែលបាន ប្រព្រឹត្តឡើងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ២០០១) (ហៅថាច្បាប់អ.វ.ត.ក) ហើយ (យោងតាមដីកាបញ្ជូនរឿងឱ្យស៊ើបអង្កេតលេខ ០៤៤/០២ ចុះថ្ងៃទី២០ ខែកុម្ភៈឆ្នាំ២០០២) គេចោទប្រកាន់គាត់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការចោទនេះត្រូវបានឆ្លើយតបជាបន្ទាន់តាមរយៈការស៊ើបអង្កេតមួយជាមួយនឹងដីកាឱ្យឃុំខ្លួន (លេខ ១០/០៣/DK ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០២)។ រយៈពេលបីឆ្នាំជាបន្តបន្ទាប់ (២០០៣ ២០០៤ ២០០៥) ចៅក្រមស៊ើបអង្កេតបានចេញដីកាឃុំខ្លួនថ្មីមួយនៅថ្ងៃទី២២ ខែកុម្ភៈ បញ្ជាក់ពីហេតុផលរាល់ការបន្ថែមរយៈពេលជាបន្តបន្ទាប់ក្នុងការឃុំខ្លួន កាំង ហ្គេច អ៊ាវ មុនការជំនុំជម្រះដោយចៅក្រម

[៦] Decree Law 1 គឺជាច្បាប់ដែលត្រូវបានអនុម័តលើកដំបូងគេដោយសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលជារបបមួយបានបណ្តេញកម្ពុជាប្រជាធិបតេយ្យ ហើយបានបន្តវាយប្រយុទ្ធឆ្លងកាត់រយៈពេលនៃទសវត្សរ៍ទី៨០។ ច្បាប់នេះមានគោលបំណងផ្តល់មូលដ្ឋានផ្លូវច្បាប់មួយសំរាប់តុលាការបដិវត្តប្រជាជន ជាតុលាការដែលត្រូវបានបង្កើតឡើងនៅក្រុងភ្នំពេញក្នុងរដូវក្តៅឆ្នាំ១៩៧៩ ដើម្បីជំនុំជម្រះទោសក្រុម ប៉ុល ពត អៀង សារី។

00154365

ស៊ើបអង្កេតមានបំណង "អនុវត្តនូវការស៊ើបអង្កេតដ៏ល្អមួយ"។ កាំង ហ្គេច អ៊ាវ ត្រូវបានចោទប្រកាន់ជាថ្មីម្តងទៀតក្នុងឆ្នាំ២០០៥ ដោយផ្អែកលើមាត្រា៦ និង៨ នៃច្បាប់អ.វ.ត.ក ហើយបានកំណត់ប្រភេទនៃការចោទប្រកាន់នោះថាជា "ឧក្រិដ្ឋកម្មសង្គ្រាម [និង] ឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលទទួលបានការការពារជាអន្តរជាតិ" (ដីកាបញ្ជូនរឿងឱ្យស៊ើបអង្កេត លេខ ០០៤/05 ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥) ជាមួយនឹងការបន្ថែមរយៈពេលឃុំខ្លួនមុនការជំនុំជម្រះរបស់គាត់ មានប្រសិទ្ធិភាពអនុវត្តដោយដីកាឃុំខ្លួនមួយដែលរៀបចំឡើងភ្លាម ដោយចៅក្រមស៊ើបអង្កេត (លេខ ០៨#05 ចុះថ្ងៃទី២៨ ខែកុម្ភៈ)។ ចៅក្រមស៊ើបអង្កេត បានបន្តរៀបចំចេញដីកាឃុំខ្លួនផ្អែកលើការចោទប្រកាន់ដែលកំពុងធ្វើឡើង ហើយអនុលោមតាមច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន (មុនការជំនុំជម្រះ) (១៩៩៩) (ហៅថាច្បាប់ស្តីពីការឃុំខ្លួន) ឆ្នាំ២០០៦ និង២០០៧។ ជនជាប់ឃុំត្រូវបានចោទប្រកាន់ជាថ្មីពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដោយអ.វ.ត.ក ផ្អែកលើមាត្រា៥ និង២៩(ថ្មី) ៣៩(ថ្មី)នៃច្បាប់អ.វ.ត.ក ដែលមាត្រាទាំងពីរគឺ (មាត្រា៥ និង៣៩) មានភាពដូចគ្នានឹងការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិប្រឆាំង នឹង កាំង ហ្គេច អ៊ាវ ដោយតុលាការយោធាក្រុងភ្នំពេញ។ ការចោទប្រកាន់នេះបាននាំឱ្យមានការចេញដីកាឃុំខ្លួន ដែលចែងថា ការឃុំខ្លួនអនុលោមតាមដីកានេះគឺមានរយៈពេល "មិនលើសពីរយៈពេលមួយឆ្នាំឡើយ"។ គ្មានការចោទប្រកាន់ណាមួយកន្លងមកចំពោះ កាំង ហ្គេច អ៊ាវ ត្រូវបានគេនិយាយនៅក្នុងដីកាឃុំខ្លួននោះទេ ហើយក៏ពុំមានសេចក្តីយោងទៅលើច្បាប់ផ្សេងទៀតដែរ ក្រៅពីច្បាប់ទាំងឡាយដែលមាននៅក្នុងកម្រងច្បាប់តុលាការ ដូចជា(ច្បាប់បង្កើតអ.វ.ត.ក + វិធានផ្ទៃក្នុងអ.វ.ត.ក)។

## ដំណោះស្រាយបញ្ហាក្នុងសារណានេះ

មានបញ្ហាមួយ ដែលអង្គបុរេជំនុំជម្រះ ចាំបាច់ត្រូវឆ្លើយនៅដំណាក់កាលនៃការឃុំខ្លួន កាំង ហ្គេច អ៊ាវ ពោលគឺដំណាក់កាលដីកាឃុំខ្លួនមុនការជំនុំជម្រះបច្ចុប្បន្នរបស់សហចៅក្រមស៊ើបអង្កេតគួរត្រូវលុបចោល ឬយ៉ាង?។

ដោយហេតុថា បញ្ហានៃការឃុំខ្លួន កាំង ហ្គេច អ៊ាវ បច្ចុប្បន្ន និងការឃុំខ្លួនពីមុនមានការស្មុគស្មាញមួយ ដំណោះស្រាយគឺ តម្រូវឱ្យមានការពិនិត្យគ្រប់ជ្រុងជ្រោយទៅលើបញ្ហាជាឫសគល់មួយចំនួនធំ។ ទីមួយគឺ អង្គបុរេជំនុំជម្រះ ត្រូវធ្វើការពិនិត្យមើលអំពីសេចក្តីសំអាងរបស់សហចៅក្រមស៊ើប

អង្កេតដែលថា ជនជាប់ឃុំថិតក្នុងស្ថានភាពនាំឱ្យមានគ្រោះថ្នាក់ ហើយប្រសិនបើមានការដោះ លែង ជននេះឱ្យនៅក្រៅឃុំរង់ចាំការជំនុំជម្រះនោះវានឹងនាំទៅរក ក) ការដាក់សម្ពាធទៅលើសាក្សី ខ)យោង តាមសកម្មភាពទាំងឡាយដែលអាចសម្របសម្រួលដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ គ)បង្កការរំខាន ដល់សណ្តាប់ធ្នាប់សាធារណៈ។ ទីពីរ អង្គបុរេជំនុំជម្រះត្រូវធ្វើការពិនិត្យលើទ្រឹស្តីរបស់សហចៅក្រម ស៊ើបអង្កេតអំពីតួនាទី ដែលអ.វ.ត.ក ត្រូវបំពេញក្នុងប្រព័ន្ធតុលាការកម្ពុជា ដែលទ្រឹស្តី នោះនឹងធ្វើជាវិភាគទានដល់ការបង្កើតទ្រឹស្តីអង្គបុរេជំនុំជម្រះអំពីទំនាក់ទំនងរវាងអ.វ.ត.កនិងតុលាការ យោធាក្រុងភ្នំពេញ។នៅពេលទ្រឹស្តីទំនាក់ទំនងរបស់អង្គបុរេជំនុំជម្រះត្រូវបង្កើតភ្លាម អង្គបុរេជំនុំជម្រះ អាចឆ្លើយសំនួរទាក់ទងនឹង ក)រយៈពេល ខ)មូលដ្ឋានច្បាប់ទាំងមូល ឬជាផ្នែក អំពីការឃុំខ្លួន កាំង ហ្គិច អ៊ាវ ពីមុនមក ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ដល់ការបង្កើតអ.វ.ត.ក។ ជាបញ្ចប់ អង្គ បុរេជំនុំជម្រះ ចាំបាច់ត្រូវធ្វើការពិនិត្យអំពីភាពពាក់ព័ន្ធនៃករណីយុត្តិសាស្ត្រ ទាំងជាតិ និងអន្តរជាតិ ដែលសហចៅក្រមស៊ើបអង្កេតបាពោលដល់ ដើម្បីគាំទ្រដល់ការវែកញែករបស់ខ្លួន ក្នុងការបន្តឃុំខ្លួន កាំង ហ្គេច អ៊ាវ មុនការជំនុំជម្រះ។

*ភាគីអញ្ញាក្រិត្យក្នុងរឿងក្តី* ពុំមានវិធីណាកំណត់អំពីថាតើ ជនជាប់ឃុំបង្ហាញនូវ ស្ថានភាព គ្រោះថ្នាក់ឡើយ ហើយប្រសិនបើដូច្នោះមែននោះ គាត់បង្ហាញនូវស្ថានភាពគ្រោះថ្នាក់ក្នុង កម្រិតណា។ *ភាគីអញ្ញាក្រិត្យក្នុងរឿងក្តី* ពុំអាចជួបជាមួយជនជាប់ឃុំដើម្បីព្យាយាម កំណត់ពីផ្នត់គំនិតរបស់គាត់ ទាក់ទងនឹងសកម្មភាពនានា ដែលគាត់ទទួលខុសត្រូវ ប្រសិនបើមានការ ដោះលែងឱ្យនៅក្រៅឃុំរង់ចាំ ការជំនុំជម្រះ។ *ភាគីអញ្ញាក្រិត្យក្នុងរឿងក្តី* នឹងមិនទាក់ទងក្នុងបញ្ហានៃ ការប្រមើមើលខ្ពស់ពី ប្រតិកម្មរបស់សាធារណៈទូទៅចំពោះការដោះលែង កាំង ហ្គេច អ៊ាវ រួមទាំងការ រង់ចាំការជំនុំជម្រះ ឬមិនទាក់ទងជាមួយនឹងលទ្ធផលនៃការបណ្តាលមកពីការលុបចោលកិច្ចដំណើរ ការនីតិវិធីចំពោះរូប គាត់ឡើយ និងកម្រិតសុវត្ថិភាពដែលគាត់មាន ប្រសិនបើត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។ *ភាគីអញ្ញាក្រិត្យក្នុងរឿងក្តី* នឹងមិនពាក់ព័ន្ធក្នុងការពិភាក្សាទ្រង់ទ្រាយធំណាមួយឡើយអំពីភាពពាក់ព័ន្ធ នៃករណីយុត្តិសាស្ត្រ ហើយដែលសហចៅក្រមស៊ើបអង្កេតបាន សំអាងជាមូលហេតុ សំរាប់ឃុំខ្លួន កាំង ហ្គេច អ៊ាវ ក្នុងអ.វ.ត.ក លើកលែងតែ ការចោទសួរអំពីការប្រើប្រាស់ករណីយុត្តិ សាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត និងភាពពាក់ព័ន្ធរបស់គេ ទៅនឹងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក និងករណីយុត្តិសាស្ត្រជាតិដែលទទួលបានការចាប់អារម្មណ៍ពីសាធារណៈជនខ្ពស់ (ដូចជា *Scott, Eichmann ។ល។*) ដើម្បីបញ្ចូលទៅក្នុងការចងក្រងជាច្បាប់អន្តរជាតិ ហើយដែលសព្វថ្ងៃ

00154367

ពុំទាន់មានការព្រៀងគ្នារវាងអ្នកប្រាជ្ញច្បាប់នៅឡើយ។ ជាពិសេស វាជាការអនុវត្តករណីយុត្តិសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតបានពោលថា ការអនុវត្តនេះ បានបង្កើតឡើងតាំងតែពីមុនការចូលជាធរមាននៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដែលមេធាវីការពារក្តី ឈរលើការវែកញែករបស់ខ្លួនក្នុងការដោះលែងជនជាប់ឃុំ(Detainee)ឱ្យនៅក្រៅឃុំ។

ហេតុដូច្នេះ ការធ្វើវិភាគទានរបស់*ភាគីអព្យាក្រិត្យក្នុងរឿងក្តី* មានកម្រិតក្នុងពិនិត្យមើលអង្គច្បាប់ ដែលភាគីនេះជឿថា អង្គច្បាប់ធ្លាក់ទៅលើព្រំដែននៃទ្រឹស្តីទំនាក់ទំនងមួយ ដែលអាចមានរវាងអ.វ.ត.ក និងប្រព័ន្ធតុលាការដទៃទៀត *ភាគីអព្យាក្រិត្យក្នុងរឿងក្តី* ផ្តោតជាពិសេសលើអត្ថិភាពនៃទ្រឹស្តីទំនាក់ទំនងជាមួយតុលាការយោធាក្រុងភ្នំពេញ និងពិនិត្យទៅលើនីត្យានុកោលភាពនៃការឃុំខ្លួន កាំង ហ្គិច អ៊ាវ ពីមុនមក និងឥទ្ធិពលដែលអាចលើប្រព័ន្ធតុលាការកម្ពុជាទាំងមូល ប្រសិនបើអង្គបុរេជំនុំជម្រះទុកចោលមិនលើកយកមកដោះស្រាយទេនោះ។

## សេចក្តីសំអាងសង្ខេប

សារណានេះសូមស្នើនូវសេចក្តីសំអាងដូចខាងក្រោម និងសូមធ្វើការបញ្ជាក់ដូចតទៅ៖ (១) អ.វ.ត.កត្រូវបង្កើតឡើងលើមូលដ្ឋានច្បាប់មួយដែលត្រូវបានអនុម័តដោយរដ្ឋសភាកម្ពុជា មានបំណងប្រតិបត្តិការជាយុត្តាធិការកម្ពុជាឯកទេសមួយក្នុងរចនាសម្ព័ន្ធដែលមានស្រាប់នៃតុលាការកម្ពុជា (២) ច្បាប់កម្ពុជាមានអាទិភាពនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក ហើយច្បាប់អន្តរជាតិដើរតួនាទីមួយដែលច្បាប់កម្ពុជាមានភាពចន្លោះប្រហោង ពោលគឺច្បាប់អន្តរជាតិនឹងត្រូវអនុវត្តក្នុងករណីដែលច្បាប់កម្ពុជាពុំមានលក្ខណៈច្បាស់លាស់ ឬមានវិវាទជាមួយបទដ្ឋានយុត្តិធម៌អន្តរជាតិដែលបានបង្កើតឡើង (៣) ផ្អែកលើកត្តាជាច្រើន ដែលអង្គបុរេជំនុំជម្រះមានយុត្តាធិការត្រួតពិនិត្យការឃុំខ្លួន កាំង ហ្គិច អ៊ាវ មុនអ.វ.ត.ក (៤) ការឃុំខ្លួន កាំង ហ្គិច អ៊ាវ មុនអ.វ.ត.ក គឺជាការខុសច្បាប់ដោយមូលហេតុខាងក្រោម៖ (ក) តុលាការយោធាក្រុងភ្នំពេញពុំមានយុត្តាធិការទៅលើ កាំង ហ្គិច អ៊ាវ ឡើយ (ខ) ច្បាប់ដែលត្រូវបានប្រើប្រាស់ក្នុងចោទប្រកាន់ចំពោះ កាំង ហ្គិច អ៊ាវ នៅមុនពេលអ.វ.ត.ក នោះ ត្រូវបានចូលនិរាករណ៍ ឬកំណត់ដោយឡែកទៅហើយ ដែលច្បាប់ទាំងនោះគួរបានរារាំងកុំឱ្យតុលាការយោធាអនុវត្ត។ (គ) ក្នុងអំឡុងពេល៨ឆ្នាំនៃការឃុំខ្លួនមុនអ.វ.ត.ក តុលាការយោធាបានដំណើរការស៊ើប អង្កេតគ្មានគុណភាព ដើម្បីបង្ហាញពីការឃុំខ្លួន កាំង ហ្គិច អ៊ាវ លើសរយៈពេល (ឃ) ការបន្ថែមអាជ្ញា យុ

00154368

កាលជាបន្តបន្ទាប់តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានធ្វើឱ្យ ប៉ះពាល់ដល់សិទ្ធិរបស់ កាំង ហ្គិច អ៊ាវ ក្រោមច្បាប់ជាតិ និងអន្តរជាតិ (៤) សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដើម្បីដាក់ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះ កាំង ហ្គិច អ៊ាវ ទោះបីវាមិនរំលោភទៅលើគោលការណ៍ *ne bis in idem* ក៏ដោយ ក៏វាជាការសម្រេចមួយដាក់គាត់ទៅក្នុងការប្រឈមមុខឃុំខ្លួនពីរដងចំពោះបទល្មើសតែមួយ វាជាការសម្រេចចោទប្រកាន់ដោយផ្អែកលើច្បាប់តែមួយពីមុនមក។

## ១. ការកំណត់ស្ថានភាពយុត្តាធិការរបស់អ.វ.ត.ក និងសារៈសំខាន់នៃច្បាប់ (ជាតិ និងអន្តរជាតិ)

ការពិភាក្សាអំពីចរិតនៃតុលាការមួយសំរាប់ជំនុំជម្រះសមាជិកខ្មែរក្រហម ផ្តួចផ្តើមឡើងដោយនាយករដ្ឋមន្ត្រីទីមួយ នរោត្តមរណរិទ្ធិ និងនាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន បញ្ជូនលិខិតស្នើសុំមួយច្បាប់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅឆ្នាំ១៩៩៧។ នៅក្នុងចំណោមបញ្ហាផ្សេងៗ លិខិតនោះបានលាតត្រដាងអំពីបញ្ហានៃតុលាការ ដែលសហនាយករដ្ឋមន្ត្រីបានស្វះស្វែងរកបង្កើត។ កត្តាសំខាន់ជាឫសគល់ ត្រូវបានបញ្ជាក់នៅលើសំណើនោះជាតុលាការ"អន្តរជាតិ" ហើយបញ្ជាក់បន្ថែមទៀតថាការស្វែងរកជំនួយរបស់សហប្រជាជាតិសំរាប់មូលនិធិតុលាការ គឺមានលក្ខណៈដូចគ្នានឹង "សាលាក្តីបទឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតយូហ្គូស្លាវី(ICTY) និងសាលាក្តីបទឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសរវ៉ាន់ដា (ICTR)"[៧]

ក្នុងឆ្នាំ១៩៩៩ ទស្សនៈនៅពីក្រោយសំណើឆ្នាំ១៩៩៧នោះ ក្រោយមកមានផ្លាស់ប្តូរទៅជាការស្នើសុំជំនួយសហប្រជាជាតិ ដើម្បីបង្កើតតុលាការមួយក្នុងប្រព័ន្ធតុលាការកម្ពុជា[៨]។ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៩៩ ប្រទេសកម្ពុជា បាននិយាយទទួចលើសេចក្តីថ្លែងការណ៍ពីមុនមករបស់ខ្លួនអំពីចរិតលក្ខណៈនៃតុលាការសំរាប់ការស្វែងរកជំនួយរបស់អង្គការសហប្រជាជាតិ ម្តងនេះពិពណ៌នាថាជា "តុលាការជាតិមួយ"។ បន្ទាប់មកនៅក្នុងខែនោះដែរ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងកិច្ចសម្ភាសន៍មួយ

[៧] លិខិតចម្លងមួយច្បាប់មាននៅលើឯកសាររបស់*ភាគីអញ្ញត្រកិច្ចក្នុងរឿងក្តី*។

[៨] បញ្ហានេះបានកើតឡើងដោយចៃដន្យពីរថ្ងៃបន្ទាប់ពីក្រុមអ្នកជំនាញការមួយសំរាប់ប្រទេសកម្ពុជា ដោយអនុលោមតាមសេចក្តីសម្រេចមហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ៥២/១៣៥ ចេញផ្សាយរបាយការណ៍មួយអំពីលទ្ធផលរបស់ខ្លួនរិះគន់ប្រព័ន្ធតុលាការកម្ពុជាថា "ខ្វះឯករាជភាព អនាគតិ និងគ្មានសមត្ថភាព"។

00154369

ជាមួយនឹងកាសែតជប៉ុន[៩] បានបន្ថែមលើអត្ថន័យនៃពាក្យ "តុលាការជាតិ" ហើយអះអាងថា ដំណើរការនីតិវិធីរបស់តុលាការត្រូវ "ប្រព្រឹត្តិទៅដោយតុលាការកម្ពុជាដែលមានស្រាប់ និងជាមួយជំនួយអន្តរជាតិ និងការចូលរួមពីចៅក្រមនិងព្រះអាជ្ញាបរទេស"។ ភាសានេះមានចែងយ៉ាងច្បាស់នៅក្នុងអត្ថបទកិច្ចព្រមព្រៀង ដែលបានធ្វើឡើងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ មាត្រា១២នៃកិច្ចព្រមព្រៀងចែងថា "នីតិវិធីត្រូវអនុលោមតាមច្បាប់កម្ពុជា" ខបញ្ញត្តិនេះចែងសំរាប់ជាសារដាស់តឿនដល់ក្រុមអ្នកច្បាប់តុលាការ អាចជួយដល់វិធាននីតិវិធីដែលបានបង្កើតឡើង អនុវត្តទៅបានតាមកម្រិតអន្តរជាតិ។ មានករណីលើកលែងមួយចំនួនដូចខាងក្រោម៖ ក)នៅចំនុចណាដែលច្បាប់កម្ពុជាមិនអាចដោះស្រាយជាមួយបញ្ហាពិសេស ខ) នៅចំនុចណាដែលមានភាពមិនប្រក្រតីទាក់ទងនឹងការបកស្រាយ ឬការអនុវត្តវិធានច្បាប់កម្ពុជាពាក់ព័ន្ធ គ)នៅចំនុចណាដែលមានបញ្ហាទាក់ទងនឹងសង្គតភាពវិធានបែបនេះជាមួយនឹងបទដ្ឋានអន្តរជាតិ។ មាត្រា៣៣(ថ្មី)នៃច្បាប់បង្កើតអ.វ.ត.កសង្កត់ធ្ងន់ទៅលើគោលការណ៍ទាំងនេះ ហើយបញ្ជាក់ថា កិច្ចដំណើរការនីតិវិធីត្រូវតែធ្វើឡើង "អនុលោមតាមនីតិវិធីជាធរមានដែលមានស្រាប់"។

សេចក្តីថ្លែងការណ៍នយោបាយកន្លងមក ដែលក្រោយមកបានក្លាយជាភាសាច្បាប់បង្កើតបានជាអ.វ.ត.ក ដែលជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា និងបង្កើតនូវកិច្ចដំណើរការនីតិវិធីលើច្បាប់កម្ពុជាដែលមានស្រាប់។ វាជាភាពច្បាស់លាស់ចេញពីភាសានៃកិច្ចព្រមព្រៀង និងច្បាប់បង្កើតអ.វ.ត.ក ដែលគេអាចស្វែងរកការបំភ្លឺអំពីការបង្កើតវិធាននីតិវិធីនានាក្នុងកម្រិតអន្តរជាតិ ក្នុងមធ្យោបាយចុងក្រោយបំផុត និងបន្ទាប់ពីមានការពិនិត្យបានត្រឹមត្រូវលើនីតិវិធីដែលបានបង្កើតក្នុងស្រុក។ សហចៅក្រមស៊ើបអង្កេតបានធ្វើព្រងើយអំពីវិធាននេះក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន ដែលបានចេញចំពោះ កាំង ហ្គិច អ៊ាវ។ សហចៅក្រមស៊ើបអង្កេតយល់ខុសលើភាសាមាត្រា១២នៃកិច្ចព្រមព្រៀង ដែលពួកគាត់សន្និដ្ឋានទៅលើ "មាត្រានេះចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនអនុលោមតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ" ការបកស្រាយអត្ថបទនេះប្រៀបបីដូចជាសេចក្តីថ្លែងការណ៍មួយអំពីអាទិភាពនៃច្បាប់អន្តរជាតិ ដែលជាការបកស្រាយមួយស្រដៀងនឹងអ្វីដែលសហប្រជាជាតិ បានបង្កើតឡើងពីមុនមកនូវតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ការវែកញែកនេះគឺជាការវែកញែកមិនអាចការពារបានចំពោះហេតុផលពីរយ៉ាង។ ហេតុផលទីមួយគឺ ការបកស្រាយអំពីចរិតលក្ខណៈនៃមាត្រា១២ក្នុង

[៩] ទស្សនៈថ្មីរបស់កម្ពុជា ទីភ្នាក់ងារព័ត៌មានKyoto លេខ២០ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

ការបញ្ចូល ខ បញ្ញត្តិ ដែលទាក់ទងនឹងការបង្កើតអាទិភាពនៃច្បាប់កម្ពុជាក្នុងកថាខណ្ឌទីមួយនៃមាត្រានេះ ដែលមានលក្ខណៈបើកចំហជាមួយនឹងឃ្លាថា "ត្រូវអនុលោមតាមនីតិវិធីនៃច្បាប់កម្ពុជា" ដែលចំនុចនេះបង្ហាញឱ្យឃើញថា គោលបំណងរបស់អ្នកធ្វើសេចក្តីព្រាង ចង់ធានាដល់អាទិភាពនៃច្បាប់កម្ពុជា ក្នុងការប្រព្រឹត្តទៅរបស់អ.វ.ត.ក។ ហេតុផលទីពីរ មាត្រា១២ ដែលគោរពតាម "បទដ្ឋានយុត្តិធម៌អន្តរជាតិ" ពុំមានលក្ខណៈទូលំទូលាយដូចគោលបំណងរបស់សហចៅក្រមស៊ើបអង្កេតចង់ដឹកនាំពួកយើងឱ្យជឿនោះឡើយ។ តាមពិត ភាសានៃកថាខណ្ឌក្នុងមាត្រា១២ ចែងច្បាស់យោងទៅលើបទដ្ឋានយុត្តិធម៌អន្តរជាតិនានា ដែលមានចែងក្នុងមាត្រា១៤ និង១៥នៃច្បាប់ICCPR ដែលជាការកំណត់ដោយប្រសិទ្ធិភាពអំពីវិសាលភាពជាចំបងនៃ ខ បញ្ញត្តិ "បទដ្ឋានយុត្តិធម៌អន្តរជាតិ"ដើម្បីការប្រព្រឹត្តិទៅរបស់អ.វ.ត.ក។ នេះគឺជាបង្ហាញយ៉ាងច្បាស់មួយអំពីឋានានុក្រមច្បាប់ ដែលបង្កើតឡើងដោយច្បាប់បង្កើតអ.វ.ត.ក និងកិច្ចព្រមព្រៀង ដែលដាក់ច្បាប់កម្ពុជាក្នុងស្ថានភាពមួយមានអាទិភាព ហើយទុកច្បាប់អន្តរជាតិក្នុងស្ថានភាពមួយគ្រាន់តែជាការបំពេញបន្ថែមនោះ[១០]។

សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា អ.វ.ត.ក ពុំបានធ្វើការ "ជាមួយតុលាការយោធាក្រុងភ្នំពេញ" ចាប់តាំងពីដើមមករហូតដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧។ លក្ខណៈយុត្តាធិការរបស់អ.វ.ត.កដែលផ្អែកលើច្បាប់កម្ពុជា ពុំមានចែងអំពីការរួចផុតពីបន្ទុកដោះស្រាយបញ្ហាទាំងឡាយនៃការឃុំខ្លួនលើកមុន ក្នុងយុត្តាធិការជាតិផ្សេងទៀតទេ។ តាមពិត តុលាការនៅក្នុងប្រទេសកម្ពុជា ត្រូវបានផ្តល់សិទ្ធអំណាចដូច ការទទួលខុសត្រូវដូចគ្នា ក្រោមច្បាប់កម្ពុជា[១១]។ ហេតុដូច្នេះ *ភាគីអញ្ញាក្រិត្យក្នុងរឿងក្តីនេះ* អះអាងថា វាពុំមានការវែកញែកត្រឹមត្រូវណាមួយអាចគាំទ្រដល់សេចក្តីអះអាងរបស់សហចៅក្រមស៊ើបអង្កេត ដែលថា អ.វ.ត.កពុំមានយុត្តាធិការត្រួតពិនិត្យដីកាឃុំខ្លួន កាំង ហ្គិច អ៊ាវ ដែលចេញដោយចៅក្រមស៊ើបអង្កេតតុលាការយោធាក្រុងភ្នំពេញ កាលពីលើកមុននោះឡើយ ទោះជាផ្អែកលើ ខ បញ្ញត្តិ ឬករណីយុត្តិសាស្ត្រណាក៏ដោយ។ ជាងនេះទៅទៀត វាជាសារៈសំខាន់ណាស់ក្នុងការកត់សំគាល់ថា គ្មានករណីយុត្តិសាស្ត្រណា ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងដីកាឃុំខ្លួនបណ្តោះអាសន្នចំពោះ កាំង ហ្គិច អ៊ាវ កើតមាននៅក្នុងសំណុំរឿងទាំងឡាយ ដែលផ្ទុះបញ្ចាំងពីគំរូ

---

[១០] សេចក្តីថ្លែងការណ៍នេះពុំគួរបកស្រាយធ្វើឱ្យប៉ះពាល់ដល់ច្បាប់អន្តរជាតិ ដែលប្រទេសកម្ពុជាបានប្រកាន់ខ្ជាប់ និងធ្វើឱ្យប៉ះពាល់ដល់បញ្ចូលច្បាប់ទាំងនោះ ទៅក្នុងការចងក្រងជាច្បាប់កម្ពុជាឡើយ។

[១១] ច្បាប់ស្តីពីការរៀបចំតុលាការ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣។

យុត្តាធិការស្រដៀងគ្នាមួយ ដែលអ.វ.ត.ក ធ្វើប្រតិបត្តិការនោះឡើយ ពោលគឺ តុលាការពិសេសមួយ ដែលមានការចូលរួមពីអន្តរជាតិក្នុងយុត្តាធិការជាតិមួយ។

## ២. ភាពត្រឹមត្រូវនៃការឃុំខ្លួន កាំង ហ្គិច អ៊ាវ នៅមុនពេលអ.វ.ត.ក

មុនចូលដល់ការពិភាក្សាទូលំទូលាយធំអំពីការឃុំខ្លួន កាំង ហ្គិច អ៊ាវ នៅមុនពេលអ.វ.ត.ក ហើយវាជាសារៈសំខាន់ណាស់ក្នុងការកត់សំគាល់ថា រយៈពេលនៃការឃុំខ្លួននោះគឺបានដល់ថ្ងៃកំណត់ រំពឹងទុកចំពោះការបង្កើតអ.វ.ត.ក ដែលមានការពន្យាពេលជាច្រើនលើក ដោយកត្តាទាំងឡាយដែល មិនទាក់ទងនឹងតុលាការកម្ពុជា ឬជនជាប់ឃុំ (detainee)[១២]។ គោលបំណងនៃការឃុំខ្លួននេះ ត្រូវបាន បញ្ជាក់ដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជាមុនការបង្កើតអ.វ.ត.ក[១៣]។ ចំពោះការបន្ថែមរយៈ ពេលឃុំខ្លួនជនជាប់ឃុំពីររូបគឺ កាំង ហ្គិច អ៊ាវ និងអ៊ុង ជឿន គឺមានគោលបំណងធានាដល់សហគមន៍ អន្តរជាតិថា រាជរដ្ឋាភិបាលកម្ពុជានឹងអាចប្រគល់ខ្លួនចុងចោទបាន ប្រសិនបើអ.វ.ត.កត្រូវបានបង្កើត ឡើង។ ប្រសិនបើនេះមិនមែនជាករណីរង់ចាំការបង្កើតអ.វ.ត.ក ទេនោះ ជនជាប់ឃុំ(detainee) គួរ ត្រូវបានជំនុំជម្រះដោយតុលាការជាតិមួយដែលមានយុត្តាធិការធ្វើទៅបាន។

មុនការអនុម័តច្បាប់ស្តីពី ការបង្កើតអ.វ.ត.ក ពុំមានអ្វីអាចរារាំងតុលាការជាតិមួយពីការជំនុំជម្រះ កាំង ហ្គិច អ៊ាវ ឡើយ។ នេះគឺ ជាកត្តាមួយល្អ ដែលសហគមន៍អន្តរជាតិបានដឹងឮ។ វានឹងជាការអនុវត្តមួយគ្មានខ្លឹមសារប្រសិន បើ អ.វ.ត.កនៅបន្តព្យាយាមធ្វើព្រងើយកន្តើយពីបញ្ហានេះ។

## ២.១ ការចោទប្រកាន់នៅមុន អ.វ.ត.ក ដោយផ្អែកលើច្បាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា

---

[១២] ដើម្បីជាប្រយោជន៍ដល់ប្រសិទ្ធិភាពនៃការប្រើប្រាស់សេរីភាពនិងការគ្រប់គ្រងសារណានេះ *ភាគីអញ្ញាក្រិត្យក្នុងរឿងក្តីនេះ*នឹងមិនចូលដល់ការពិភាក្សាទូលំទូលាយធំណាមួយអំពីជីវប្រវត្តិនិងការពិភាក្សាទាក់ទងនឹងអ.វ.ត.កឡើយ។ មានការបោះពុម្ពផ្សាយមួយចំនួនធំអំពីបញ្ហានេះ ដែលនឹងជួយដល់អង្គបុរេជំនុំជម្រះ ក្នុងករណីចាំបាច់។

[១៣] *Supra 9*

00154372

ការឃុំខ្លួន កាំង ហ្គិច អ៊ាវ នៅមុន អ.វ.ត.ក ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានច្បាប់ជាបន្តបន្ទាប់ ដែលអនុម័តដោយរបបខុសៗគ្នាជាច្រើន ដែលបានធ្វើការគ្រប់គ្រងប្រទេសកម្ពុជារវាងឆ្នាំ១៩៧៩ និងឆ្នាំ១៩៩៩។ ច្បាប់Decree law 1 (១៩៧៩) (បានបង្កើតតុលាការបដិវត្តន៍ប្រជាជន) ច្បាប់ Decree law 2 (១៩៨០) (ក្រមព្រហ្មទណ្ឌនៃតុលាការបដិវត្តប្រជាជន) និងមាត្រាមួយចំនួនរបស់ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក (២០០១ ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០០៤)។ ខាងក្រោមនេះគឺជាប្រព្រឹត្តិកម្មដោយឡែកពីគ្នាអំពីច្បាប់ដែលបានពោលពីខាងដើម។

Decree law 1 ជាមូលដ្ឋានក្នុងចោទប្រកាន់ កាំង ហ្គិច អ៊ាវ ពីបទប្រល័យពូជសាសន៍ ដែលត្រូវបានអនុម័តនៅឆ្នាំ១៩៧៩ ដោយសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលទើបបង្កើតថ្មីនៅពេលនោះ ហើយដែលមានបំណងបង្កើតតុលាការមួយដើម្បីជំនុំជម្រះក្រុម ប៉ុល ពត-អៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ពាក្យប្រល័យពូជសាសន៍ ត្រូវបានគេកំណត់និយមន័យនៅក្នុងមាត្រា១នៃច្បាប់ Decree law 1ថា។

"ជាការសម្លាប់រង្គាលចំពោះក្រុមមនុស្សស្លូតត្រង់ដោយមានផែនការទុកជាមុន ការបណ្តេញចេញប្រជាជនចេញពីទីក្រុងនិងភូមិក្នុងគោលបំណងប្រមូលផ្តុំមនុស្សឱ្យធ្វើការធ្ងន់ ក្នុងលក្ខខណ្ឌទាំងឡាយ ដែលនាំទៅរកការបំផ្លិចបំផ្លាញសតិបញ្ញាស្មារតី និងរាងកាយ លុបបំបាត់ចោលសាសនា បំផ្លាញចោលរចនាសម្ព័ន្ធវប្បធម៌ សង្គម និងនយោបាយ និងទំនាក់ទំនងគ្រួសារនិងសង្គម។"

និយមន័យនេះមានលក្ខណៈផ្ទុយទៅនឹងនិយមន័យមាត្រា២នៃសន្ធិសញ្ញា ស្តីពីការការពារនិងការដាក់ទោសទណ្ឌបទឧក្រិដ្ឋប្រល័យពូជសាសន៍ (១៩៤៨) (ឬហៅថា សន្ធិសញ្ញាប្រល័យពូជសាសន៍ ) ដែលត្រូវគេកំណត់និយមន័យថា "ការអំពើណាមួយក្នុងចំណោមអំពើខាងក្រោមនេះ ដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញ ទាំងមូល ឬមួយផ្នែក នៃប្រជាជាតិមួយ ជាតិពន្ធុ ជាតិសាសន៍ ឬក្រុមសាសនា ដូចជា៖ ក)ការសម្លាប់សមាជិកក្រុម ខ)បង្កការគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយសមាជិកក្រុម គ) ដាក់ទោសទណ្ឌលើលក្ខខណ្ឌជីវិតរស់នៅរបស់ក្រុម ដែលរៀបចំឡើងដើម្បីនាំទៅរកការបំផ្លិចបំផ្លាញរាងកាយរបស់ក្រុមនោះទាំងមូល ឬជាផ្នែក ឃ) ដាក់វិធានការមានបំណងការពារកុំឱ្យមានកំណើតនៅក្នុងក្រុម ង) ផ្ទេរកុមារក្នុងក្រុមមួយទៅក្រុមមួយទៀតដោយបង្ខំ"។

ចាប់តាំងពី ប្រទេសកម្ពុជាបានឱ្យសច្ចាប័ណលើសន្ធិសញ្ញាប្រល័យពូជសាសន៍ ក្នុងឆ្នាំ១៩៥០ និយមន័យប្រល័យពូជសាសន៍ក្នុងច្បាប់កម្ពុជា ដែលមានសុពលភាពប្រើប្រាស់ គឺជានិយមន័យមួយដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងនិយមន័យដូចគ្នាក្នុងសន្ធិសញ្ញាប្រល័យពូជសាសន៍។ ហេតុដូច្នេះ

00154373

ការអនុម័តនិងការដាក់ឱ្យអនុវត្តច្បាប់ណាមួយ ដែលមាននិយមន័យផ្ទុយនឹងសន្ធិសញ្ញាប្រល័យពូជសាសន៍ ត្រូវចាត់ទុកជាមោឃៈ។ ចំនុចនេះហើយដែលធ្វើឱ្យDecree law 1 ក្លាយទៅជាមោឃៈ និងមិនអាចអនុវត្តបានចំពោះការឃុំខ្លួន កាំង ហ្គិច អ៊ាវ មុនការជំនុំជម្រះ។

Decree law 2 ត្រូវបានសាធារណៈរដ្ឋប្រជាមានិតកម្ពុជាអនុម័តនៅឆ្នាំ១៩៨០ ដែលជាច្បាប់ព្រហ្មទណ្ឌរបស់របបគ្រប់គ្រងនេះ ហើយជាច្បាប់ដែលបានដាក់ទោសព្រហ្មទណ្ឌយ៉ាងច្រើនលើសលប់ចំពោះ "អំពើទាំងឡាយប្រឆាំងនឹងបដិវត្ត"[១៤]។ ទិសដៅបដិវត្តដែលផ្អែកលើទ្រឹស្តីនិយមម៉ាកលេនីនដែលសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានប្រកាន់យកនោះ ត្រូវបានបោះបង់ចោលនៅក្នុងសមាជគណៈបក្សប្រជាជនកម្ពុជានៅថ្ងៃទី១៧-១៨ ខែតុលាការ ឆ្នាំ១៩៩០[១៥]។ Decree law 2 ឬច្បាប់ណាមួយផ្សេងទៀត ដែលសាធារណៈរដ្ឋប្រជាមានិតកម្ពុជាបានអនុម័ត មិនបានកំណត់អាជ្ញាយុកាលសំរាប់អំពើទាំងឡាយ ដែលជាបទព្រហ្មទណ្ឌទេ ហើយក៏មិនអាចធ្វើឱ្យគេដឹងអំពីរយៈពេលនៃបទល្មើសទាំងឡាយដែលត្រូវជំនុំជម្រះ និងដែលធ្លាក់ចូលទៅក្នុង "បទឧក្រិដ្ឋទាំងឡាយដែលប្រឆាំងនឹងសន្តិសុខក្នុងប្រទេស មានបំណងបំរើឱ្យគោលនយោបាយរបស់ក្រុមកម្ពុជាប្រជាធិបតេយ្យ"។ អ្វីដែលគេដឹងឮគ្រប់គ្នានោះគឺថាច្បាប់ព្រហ្មទណ្ឌថ្មី ដែលជាផ្នែកមួយនៃច្បាប់អ៊ុនតាក់នោះ និងដែលត្រូវបានចាត់ទុកជានិរាករណ៍យ៉ាងសក្តិសិទ្ធរួចទៅហើយនូវ "អត្ថបទ បញ្ញត្តិ ឬវិធានជាលាយលក្ខណ៍អក្សរ ឬគ្មានលាយលក្ខណ៍ អក្សរអ្វីមួយដែលផ្ទុយនឹងលិខិត ឬស្មារតីនៃអត្ថបទបច្ចុប្បន្ន ពោលគឺត្រូវបានទុកជាមោឃៈ"[១៦] Decree law 2 បានរំលោភយ៉ាងច្បាស់ក្រឡែតទៅលើទាំងលិខិត និងស្មារតីរបស់ច្បាប់អ៊ុនតាក់ ដែលនេះហើយគឺជា ហេតុផលដែលវាត្រូវបានចាត់ទុកជាមោឃៈយ៉ាងមានប្រសិទ្ធិភាពកាលក្នុងឆ្នាំ១៩៩២ និងអនុលោមទៅតាមសំអាងហេតុផ្លូវច្បាប់ផ្សេងៗទៀត។ ដោយពិនិត្យទៅលើអង្គហេតុក្នុងពេលចោទប្រកាន់ចំពោះ គាត់ក្នុងឆ្នាំ១៩៩៩ ច្បាប់អ៊ុនតាក់គឺជាច្បាប់ដែលឋិតជាធរមាននៅឡើយ ពោលគឺដូចក្នុងពេល សរសេរសារណានេះអញ្ចឹង កាំង ហ្គិច អ៊ាវ ពុំគួរត្រូវបានគេចោទប្រកាន់ តាមផ្លូវច្បាប់ដោយផ្អែក លើមូលដ្ឋាននៃច្បាប់ Decree Law 2 ទេ។

---

[១៤] ពាក្យដែលគេប្រើក្នុងសម័យនោះ មានន័យថាជាបទឧក្រិដ្ឋទាំងឡាយដែលប្រឆាំងនឹងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងជាពាក្យដែលសរសើរខ្លួនឯងថាជា របបមួយដែលនាំបដិវត្តកម្ពុជាដើរលើផ្លូវត្រូវ បន្ទាប់ពីបក្សកុំមុយនីសកម្ពុជាបានបង្កើតពាក្យនេះឡើង។

[១៥] Evan Gottesman, កម្ពុជាក្រោយរបបខ្មែរក្រហម៖ ក្នុងនយោបាយកសាងជាតិ Yale University Press ឆ្នាំ២០០២ ទំព័រ៣៥៤។

00154374

## ២.២ ការចោទប្រកាន់មុនពេលមាន អ.វ.ត.ក ដោយផ្អែកលើច្បាប់ អ.វ.ត.ក

ការចោទប្រកាន់របស់ អ.ត.វ.ក ផ្អែកលើ ៤ មាត្រា គឺមាត្រា ៥ ៣៤ ៦ និង ៨ ។ មាត្រាទាំងនេះកំណត់យុត្តាធិការលើរឿងក្តីរបស់ អ.ត.វ.ក ដើម្បីដោះស្រាយជាមួយបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវទទួលការការពារជាអន្តរជាតិ។ បញ្ហាដែលអង្គបុរេជំនុំជម្រះត្រូវដោះស្រាយនោះគឺថា តើតុលាការយោធាក្រុងភ្នំពេញបានប្រើប្រាស់បញ្ញត្តិច្បាប់អ្វីនៃច្បាប់ទទួលបានការអនុម័តដែលជាមូលដ្ឋានក្នុងការបង្កើត អ.ត.វ.ក ដើម្បីធ្វើការចោទប្រកាន់។ យើងមើលឃើញច្បាស់នៅក្នុងច្បាប់បង្កើតតុលាការយោធាកម្ពុជា (ច្បាប់អ៊ុនតាក់) ដែលចែងថាតុលាការនេះមានយុត្តាធិការតែលើបទល្មើសយោធាតែប៉ុណ្ណោះដែលត្រូវបានចែងនៅក្នុងច្បាប់ថាជា "...អ្នកដែលពាក់ព័ន្ធនឹងបុគ្គលិកយោធា ទោះចូលរួមដោយស្ម័គ្រចិត្ត ឬជាប់កាតព្វកិច្ចយោធា" និងបញ្ហា ២ សំខាន់ទៀត "វិន័យនៅក្នុងកងកំលាំងប្រដាប់អាវុធ" និង "ការបំផ្លិចបំផ្លាញដល់ទ្រព្យសម្បត្តិយោធា"[16]។ តាមរយៈបញ្ញត្តិច្បាប់នេះ យើងអាចនិយាយថា តុលាការយោធាក្រុងភ្នំពេញអាចមានយុត្តាធិការលើបុគ្គលម្នាក់បាន លុះត្រាតែបុគ្គលនោះបានចូលរួម ឬជាប់កាតព្វកិច្ចយោធានៅក្នុងកងយុទ្ធពលខេមរភូមិន្ទ ដែលមិនមែនជាកងកំលាំងកម្ពុជាប្រជាធិបតេយ្យ ទោះមុន ឬក្រោយពេលលោក កាំង ហ្គេច អ៊ាវ ជាមន្ត្រីនៃកងកំលាំងកម្ពុជាប្រជាធិបតេយ្យនេះ។ បញ្ហាយុត្តាធិការរបស់តុលាការយោធាក្រុងភ្នំពេញលេចឡើងច្បាស់ណាស់នៅក្នុងករណីលោក កាំង ហ្គេច អ៊ាវ ដែលថា មិនគួរមានការស៊ើបអង្កេតបន្ថែមទៀតទេ។ ដូច្នេះ សារណាសាធារណជននេះអះអាងថា តុលាការយោធាក្រុងភ្នំពេញបានអនុវត្តដោយរំលោភទៅនឹងមាត្រា ១១ នៃច្បាប់អ៊ុនតាក់ ហើយនឹងការប្រកាសជាក់លាក់លើសពីវិមតិសង្ស័យរបស់តុលាការនេះ ដែលធ្វើឲ្យលោក កាំង ហ្គិច អ៊ាវ នៅខាងក្រៅយុត្តាធិការតុលាការនេះ។ លើសពីនេះទៀត តុលាការយោធាក្រុងភ្នំពេញបានអនុវត្តដោយខុសច្បាប់ដោយប្រើប្រាស់ច្បាប់ អ.វ.ត.ក មកធ្វើការចោទប្រកាន់លោក កាំង ហ្គេច អ៊ាវ ព្រោះថា ច្បាប់ អ.វ.ត.ក នេះត្រូវបានអនុម័តក្នុងគោលបំណងតែការបង្កើតតុលាការពិសេសប៉ុណ្ណោះ ហើយចែងច្បាស់ថាមានតែ អ.វ.ត.ក ទេទើបអាចអនុវត្តច្បាប់នេះ។ សហចៅក្រមស៊ើបអង្កេតអះអាងថា អ.វ.ត.ក គ្មានកាតព្វកិច្ចពិនិត្យទៅលើការឃុំខ្លួនលោក កាំង ហ្គិច អ៊ាវ ដែលធ្វើឡើងមុនការឃុំខ្លួននៅ អ.វ.ត.ក

[16] មាត្រា ១១

00154375

ឡើយ ដោយសារ អ.វ.ត.ក មិនសហការជាមួយតុលាការយោធាក្រុងភ្នំពេញ ហើយការចោទប្រកាន់ផ្សេងៗធ្វើឡើងមុនពេលមានការបង្កើត អ.វ.ត.ក ទៀត។ ការអះអាងបែបនេះមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ។ សារណាសាធារណជននេះមានជំនឿថា ការប្រើប្រាស់ច្បាប់ អ.វ.ត.ក របស់តុលាការយោធាក្រុងភ្នំពេញក្នុងការឃុំខ្លួនមនុស្សម្នាក់ដែលបន្ទាប់មកទៀតផ្ទេរទៅ អ.វ.ត.ក ដើម្បីធ្វើការឃុំបន្តទៀត គឺជាបញ្ហាដែលអង្គបុរេជំនុំជម្រះត្រូវដោះស្រាយនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធី។

សារណាសាធារណជននេះអះអាងថា បើសិនជាគ្មានបំណងបង្កើត អ.វ.ត.ក ទេនៅពេលឃាត់ខ្លួនលោក កាំង ហ្គេច អ៊ាវ ទេ ប្រព័ន្ធតុលាការកម្ពុជាអាចនឹងបានដោះស្រាយរឿងក្តីនេះលឿនជាងនេះ[17]។ ប្រព័ន្ធតុលាការនេះគួរគ្មានមូលហេតុឃុំខ្លួនលោក កាំង ហ្គេច អ៊ាវ មុនពេលកាត់ទោសលើសពី ៨ ឆ្នាំបែបនេះទេ ដែលគួរតែជាការកាត់ក្តីលឿនមួយ ហើយយ៉ាងយូរណាស់ជាការកាត់ទោសមួយដែលមានរយៈពេលឃុំខ្លួនមុនពេលកាត់ទោសជាមធ្យមបច្ចុប្បន្នក្នុងតុលាការកម្ពុជា[18]។ សរុបសេចក្តីទៅ ដោយមិនចូលរួមនៅក្នុងការពិភាក្សាអំពីផ្នែកសំខាន់ៗនៃមាត្រាដែលបានលើកឡើងខាងលើនៅក្នុងច្បាប់ អ.វ.ត.ក សារណានេះបដិសេធយុត្តាធិការរបស់តុលាការយោធាក្រុងភ្នំពេញដែលបានប្រើប្រាស់ច្បាប់ អ.វ.ត.ក ហើយជឿថា អង្គបុរេជំនុំជម្រះបច្ចុប្បន្នមានតួនាទីដោះស្រាយបញ្ហានេះនិងផលប៉ះពាល់របស់វា។

បញ្ហាបន្ទាប់ដែលត្រូវលើកឡើងនៅក្នុងផ្នែកនេះគឺការពន្យារអាជ្ញាយុកាលដែលមានកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ "រហូតដល់ ៣០ ឆ្នាំ"[19] ចាប់ពីអំពើល្មើសដែលចោទប្រកាន់។ ច្បាប់

---

[17] ករណីលោក ឈូក រិន មេបញ្ជាការខ្មែរក្រហមឋានៈកណ្តាល បញ្ជាក់ប្រាប់យ៉ាងច្រើនអំពីល្បឿនដំណើរការដោះស្រាយក្តីរឿងខ្មែរក្រហម

[18] សារណាសាធារណជននេះមិនធ្លាប់បានដឹងអំពីការសិក្សាណាមួយស្តីពីការកំណត់រយៈពេលឃុំខ្លួនមុនពេលកាត់ទោសបច្ចុប្បន្ននៅកម្ពុជា។ តាមការរាយការណ៍ពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន យើងដឹងច្បាស់ថា ការឃុំខ្លួនមុនពេលកាត់ទោសលើសកំណត់នៅតែកើតមានច្រើន។ យ៉ាងណាក៏ដោយ រយៈពេលហួសកំណត់នេះតិចជាង ៨ ឆ្នាំ។ តាមរយៈការសិក្សាប្រព័ន្ធច្បាប់ប្រទេសកម្ពុជា សារណាសាធារណជនមិនធ្លាប់ឮរឿងក្តីណាមួយដែលមានការឃុំខ្លួនលើសកំរិតជិតដល់ ៨ ឆ្នាំឡើយ។ នេះបញ្ជាក់ថា រយៈពេលឃុំខ្លួនលើសកំណត់នេះមានរយៈពេលយូរជាងការឃុំខ្លួនជាមធ្យមក្នុងប្រទេស។

[19] ច្បាប់ អ.វ.ត.ក មាត្រា ៣ (ថ្មី)

អ.វ.ត.ក ដំបូង ដែលត្រូវបានអនុម័តនៅឆ្នាំ ២០០១ មានការពន្យារអាជ្ញាយុកាលនៃច្បាប់ព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ "រហូតដល់ ២០ ឆ្នាំ" ដែលនៅក្នុងអំឡុងពេលពន្យារនេះ អ្នកតាក់តែងសង្ឃឹមថា នឹងមានការបង្កើត អ.វ.ត.ក និងមានការកាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ប៉ុន្តែ អ្វីៗមិនបានកើតឡើងតាមការគិតនេះឡើយ។ បន្ទាប់មក អ្នកតាក់តែងបានត្រឡប់ និងកែប្រែច្បាប់ អ.វ.ត.ក ដោយពន្យារអាជ្ញាយុកាលរហូតដល់ "៣០ ឆ្នាំ"។ អ្វីដែលអង្គនីតិបញ្ញត្តិបានធ្វើនេះគឺជាសកម្មភាពជាមូលដ្ឋាន ព្រោះថាវាប៉ះពាល់ដល់គោលបំណងសំខាន់នៃយុត្តាធិការដែលត្រូវផ្តល់នូវ "ការកំណត់ចុងក្រោយ និងភាពអាចទស្សទាយទ៏បាន"[20]។ តុលាការកំពូលនៃសហរដ្ឋអាមេរិក ដែលកំណត់អាជ្ញាយុកាល បានលើកឡើងថា "អាជ្ញាយុកាល" ដូចជាលទ្ធិពន្យារពេលអហេតុដែរ គោលបំណងសំខាន់របស់វាគឺការជំរុញយុត្តិធម៌ដោយទប់ស្កាត់មិនឲ្យមានការភ្ញាក់ផ្អើលតាមរយៈការទាញយកបណ្តឹងដែលកប់ទុកយូររហូតដល់បាត់ភស្តុតាង បាត់ការចងចាំ និងបាត់សាក្សី"[21]។ នៅពេលអង្គនីតិបញ្ញត្តិមានសេរីភាពក្នុងការពន្យារអាជ្ញាយុកាលដោយគិតពីព្រឹត្តិការណ៍មួយ(ក្នុងករណីនេះការបង្កើត អ.វ.ត.ក) ជាជាងធានានូវយុត្តិធម៌ចំពោះដំណើរការនីតិវិធី នោះយើងមិនអាចកំណត់ភាពអាចទស្សទាយទ៏បាន និងការកំណត់ចុងក្រោយបានទេ។ ដូច្នេះ ទង្វើបែបនេះប៉ះពាល់ដល់ចំណុចសំខាន់នៃអាជ្ញាយុកាល និងប៉ះពាល់ខ្លាំងដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានដំណើរការតាមច្បាប់ត្រឹមត្រូវ។ ក្នុងរឿងក្តីលោក កាំង ហ្គេច អ៊ាវ អង្គបុរេនឹងត្រូវធ្វើការជ្រើសរើសស្ថានភាពលំបាកទាំងពីរ ព្រោះថាត្រូវឆ្លើយទៅនឹងសំណួរបឋមជាច្រើនមុនពេលអាចដោះស្រាយបញ្ហាសំខាន់នៃការពន្យារអាជ្ញាយុកាលសម្រាប់ការធ្វើឃាតមនុស្ស ការធ្វើទារុណកម្ម និងការធ្វើទុក្ខទោសម្នេញដល់សាសនានៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នៅក្នុងច្បាប់ អ.ត.វ.ក ឆ្នាំ ២០០១ និងការធ្វើវិសោធនកម្មនៅឆ្នាំ ២០០៤។ ចំណុចសំខាន់នៃបញ្ហានេះគឺ (១) តើការពន្យារអាជ្ញាយុកាលក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ជារឿងនយោបាយ? (២) បើដូច្នោះ តើអង្គបុរេជំនុំជម្រះអាចឆ្លើយសំណួរនយោបាយបែបនេះទេ? (៣) បើសិនជាអង្គបុរេជំនុំជម្រះយល់ថាខ្លួនត្រូវឆ្លើយសំណួរនយោបាយ តើអង្គបុរេជំនុំជម្រះអាចឆ្លើយសំណួរនេះបានទេ? (៤) តើអង្គបុរេជំនុំជម្រះត្រូវគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា

[20] Bryan A.Garner, Henry Cambell Black, Black"s Law Dictionary 1422, (West Publishing Company, 7th ed.)

[21] Order of RR Telegraphers v. Railway Express Agency, 321 U.S.342, 348-49, 64 S. Ct. 582, 586 (1944)

00154377

ដែលយល់ថាការពន្យាអាជ្ញាយុកាលនេះមានលក្ខណៈស្របច្បាប់ធម្មនុញ្ញ[22]? (5) តើអង្គបុរេជំនុំជម្រះអាចបដិសេធ កែប្រែ ឬព្រងើយកន្តើយចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាទេ? (៦) តើអង្គបុរេជំនុំជម្រះ និងក្រុមប្រឹក្សាធម្មនុញ្ញ និងអ.វ.ត.ក មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

បញ្ហាចុងក្រោយនោះគឺការដាក់សំណើរបស់តុលាការយោធាក្រុងភ្នំពេញ ដោយតុលាការនេះជារឿយៗចេញដីកាឲ្យស៊ើបអង្កេតរៀងរាល់ពេលដែលដីកាមុនជិតផុតកំណត់ ឬផុតកំណត់រួចហើយ។ អស់រយៈពេលជាង ៨ ឆ្នាំ ព្រះរាជអាជ្ញាបានដាក់សំណើចោទប្រកាន់ម្តងមួយៗក្នុងរយៈពេលយូរ ពីបទ "ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិសុខប្រទេស" "ប្រល័យពូជសាសន៍" "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" និង "ការរំលោភធ្ងន់ធ្ងរចំពោះអនុសញ្ញាក្រុងហ្សឺណែវ" រួមជាមួយនឹង "ឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវបានការពារជាអន្តរជាតិ"។ ដោយមិនចាំបាច់ពិភាក្សាអំពីផ្នែកសំខាន់ៗនៃការចោទប្រកាន់ទាំងនេះ មានសំណួរពីរដែលត្រូវឆ្លើយ: (១) អ្វីដែលរារាំងព្រះរាជអាជ្ញាទាំងអស់មិនឲ្យដាក់ការចោទប្រកាន់ទាំងនេះនៅពេលតែមួយ និងដាក់ក្នុងដីកាតែមួយឲ្យធ្វើការស៊ើបអង្កេត? និង (២) តើដីកាឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតតុលាការយោធាក្រុងភ្នំពេញមានមូលដ្ឋានផ្នែកអង្គហេតុ និងអង្គសេចក្តីអ្វីដែលពួកគាត់ចាប់ពីឆ្នាំ ២០០១ បានពន្យាររយៈពេលអតិបរមាស្របច្បាប់របស់ដីកានេះដល់ទៅ ៣ ឆ្នាំ?

*ភាគីអព្យាក្រឹត្យក្នុងរឿងក្តីនេះ*ជឿជាក់ថា ចំពោះសំណួរ(១) ពុំមានហេតុផលសមស្របណាសំរាប់ព្រះរាជអាជ្ញាដែលអាចរារាំងគាត់មិនឲ្យធ្វើការចោទប្រកាន់ក្នុងពេលតែមួយនោះទេ។ *ភាគីអព្យាក្រឹត្យក្នុងរឿងក្តីនេះ* មានគោលបំណងអះអាងថា នៅពេលចោទដំបូងឡើយ មិនទាន់មានការតាក់តែង និងអនុម័តច្បាប់ អ.វ.ត.ក នៅឡើយទេ ដែលព្រះរាជអាជ្ញាយោធាមិនអាចដឹងពីមាតិកា ហើយបង្កើតឲ្យមានការចោទប្រកាន់ពាក់ព័ន្ធបែបនេះ។ ការអះអាងនេះទោះមានមូលដ្ឋានក្តី មិនមែនមានចំណុចខ្លាំងទាំងអស់ទេ ព្រោះថា ច្បាប់ដែលការចោទប្រកាន់ផ្អែកលើច្បាប់ អ.វ.ត.ក ត្រូវបានទទួលការអនុម័តអស់រយៈពេលយូរមុនពេលមានការដាក់ការចោទប្រកាន់ដំបូងចំពោះលោក កាំង ហ្គេច អ៊ាវ[23] និងបានចូលជាច្បាប់ប្រពៃណីអន្តរជាតិរួចហើយ។ ហេតុដូច្នេះ ព្រះរាជអាជ្ញាតុលាការយោធាពុំមាន

---

[22] ក្រុមប្រឹក្សាធម្មនុញ្ញ សេចក្តីសម្រេចលេខ 040/002/2001 (02/12/01)

[23] អនុសញ្ញាក្រុងហ្សឺណែវបានទទួលការអនុម័តនៅរវាងឆ្នាំ ១៨៦៤ និង ១៩៤៩
អនុសញ្ញាក្រុងវ្យែនស្តីពីទំនាក់ទំនងការទូត នៅឆ្នាំ ១៩៦១ លក្ខខន្តិកៈតុលាការយោធាអន្តរជាតិ (សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) នៅឆ្នាំ ១៩៤៥។

ហេតុផលរង់ចាំការអនុម័តច្បាប់ស្តីពីការបង្កើតអ.វ.ត.កដើម្បីធ្វើការចោទប្រកាន់បន្ថែមទៀតឡើយ។ ចំពោះ *ភាគីអញ្យាក្រិត្យក្នុងរឿងក្តីនេះ* ដោយមិនគិតពីការអះអាងខាងលើ ការចោទប្រកាន់ទីមួយ និងទីពីរ ប្រឆាំងនឹងលោក កាំង ហ្កេច អ៊ាវ និងដែលផ្អែកលើច្បាប់កម្ពុជា គួរតែត្រូវបានចោទជាបទចោទតែមួយដែលគួរបានកាត់បន្ថយរយៈពេលឃុំខ្លួនមុនពេលកាត់ទោសជនជាប់ចោទ។

ចំពោះសំណួរ(២) ពុំមានសេចក្តីយោងណាទាក់ទងនឹងការបំពេញការងារស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតយោធា ដែលបានចេញដីកាឃុំខ្លួនក្នុងសំណុំរឿងទាំងអស់នៅពេលដែល កាំង ហ្កេច អ៊ាវ ត្រូវបានចោទប្រកាន់។ ពុំមានសេចក្តីប្រកាសណាមួយធ្វើឡើងដល់សាធារណៈជនទូទៅអំពីការរកឃើញអង្គហេតុដែលប្រមូលបានតាមរយៈកិច្ចខិតខំប្រឹងប្រែងនៃកិច្ចការស៊ើបអង្កេតទាំងនេះឡើយ។ ទោះយ៉ាងណា ដីកាឃុំខ្លួនដែលផ្អែកលើការចោទប្រកាន់តែមួយ ត្រូវបានពន្យាពេលពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់រយៈពេលអតិបរមា ៣ ឆ្នាំ ដែលច្បាប់អនុញ្ញាតក្នុងរឿងក្តីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយដីកាឃុំខ្លួននោះអមដោយសេចក្តីយោងមួយចែងថា រាល់ការឃុំខ្លួនជាបន្តបន្ទាប់គឺជាការចាំបាច់ "ដើម្បីដឹកនាំការស៊ើបអង្កេតបានល្អ"។ ការងារស៊ើបអង្កេតរយៈពេល ៨ ឆ្នាំដែលបានរាយការណ៍មក គួរបានបង្ហាញច្បាស់ដោយខ្លួនឯងអំពីភស្តុតាងទាក់ទងនឹងការចោទប្រកាន់។ អង្គបុរេជំនុំជម្រះ ដែលជាផ្នែកមួយនៃតុលាការកម្ពុជា ហើយដោះស្រាយជាមួយជនជាប់ចោទតែមួយ និងបទល្មើសតែមួយគឺ(ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជាការចោទប្រកាន់ត្រួតគ្នារវាងតុលាការយោធាក្រុងភ្នំពេញ និងអ.វ.ត.ក) អាចចេញដីកាបង្គាប់ឱ្យបង្ហាញលទ្ធផលនៃការស៊ើបអង្កេតទាំងនេះ និងត្រួតពិនិត្យមើលខ្លឹមសារនៃការស៊ើបអង្កេតនោះបន្តទៅទៀត។

*ភាគីអញ្យាក្រិត្យក្នុងរឿងក្តីនេះ* ទោះគ្មានភស្តុតាងផ្ទាល់ណាមួយក្តី ភស្តុតាងស្ថានភាពទាំងអស់បញ្ជាក់ថា រយៈពេលឃុំខ្លួន ៨ ឆ្នាំកន្លងទៅ ចៅក្រមស៊ើបអង្កេតតុលាការយោធាមិនទាន់មានការស៊ើបអង្កេត។ នេះបង្ហាញឱ្យឃើញថា តុលាការយោធាអនុវត្តសេចក្តីសម្រេចនយោបាយផង ព្រមទាំងបំរើការជាមធ្យោបាយតុលាការផង។

ក្រៅពីការរំលោភច្បាប់កម្ពុជាយ៉ាងច្បាស់ក្រឡែតរបស់តុលាការយោធា ឥរិយាបទតុលាការក៏បានផ្ទុយនឹងវិធានទាំងឡាយដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ដែលប្រទេសកម្ពុជាសន្យាថា

00154379

"ត្រូវទទួលស្គាល់ និងគោរពតាម" ក្នុងអត្ថបទរដ្ឋធម្មនុញ្ញ[24] និងដោយការផ្តល់សច្ចាប័នលើអត្ថបទច្បាប់ផ្សេងៗ ។ អត្ថបទច្បាប់មួយក្នុងចំណោមអត្ថបទច្បាប់ទាំងនោះគឺអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលបានកំណត់ពីការធានាអប្បបរមាសម្រាប់បុគ្គលទាំងឡាយក្នុងរឿងក្តីព្រហ្មទណ្ឌ។ ដូច្នេះ *ភាគីអញ្ញត្រកិត្យក្នុងរឿងក្តីនេះ* យល់ថា តុលាការយោធាក្រុងភ្នំពេញបានរំលោភសិទ្ធិលោក កាំង ហ្គេច អ៊ាវ ក្នុងការទទួលបានការកាត់ទោសដោយមិនពន្យារពេលមិនសមស្រប[25] ដែលមានចែងនៅក្នុងមាត្រា១៤ (៣) (C) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

*ភាគីអញ្ញត្រកិត្យក្នុងរឿងក្តីនេះ* យល់ថា ការឃុំខ្លួនលោក កាំង ហ្គេច អ៊ាវ ជាបន្តបន្ទាប់ក្រោមការបញ្ជារបស់តុលាការយោធា មានរយៈពេលលើសពីការកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅត្រង់ចំណុច "ការពន្យារដោយមិនសមស្រប" បើទោះជានៅកំរិតអន្តរជាតិគ្មានការកំណត់ដោយច្បាប់ច្បាស់អំពី"ការពន្យារដោយមិនសមស្រប" នេះក៏ដោយ ។

## សន្និដ្ឋាន

អង្គបុរេជំនុំជម្រះវិសាមញ្ញ មានកិច្ចការដ៏ធំធេងនៅចំពោះមុខ ពោលគឺត្រូវដោះស្រាយបញ្ហានៃការឃុំខ្លួនដែលអូសបន្លាយពេលរហូតដល់ ៨ ឆ្នាំ មុនមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយការបង្គាប់ឲ្យឃុំខ្លួននេះធ្វើឡើង ដោយសារតែសំអាងទៅលើការចោទប្រកាន់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តកាលពី ៣០ ឆ្នាំមុនមកម្ល៉េះ។ រាល់ដំណោះស្រាយអ្វីក៏ដោយដែលអង្គបុរេជំនុំជម្រះវិសាមញ្ញកំពុងរិះរក ដាច់ខាតត្រូវតែមានតុល្យភាពគ្នារវាងផលប្រយោជន៍នៃយុត្តិធម៌ចំពោះបទឧក្រិដ្ឋដ៏សាហាវ

---

[24] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[25] បើទោះជា "ការពន្យារពេលដោយមិនសមហេតុផល" មិនត្រូវបានកំណត់ច្បាស់ក៏ដោយ ក៏យុត្តាធិការដែលមានការធានាដំណើរការប្រកបដោយត្រឹមត្រូវតាមច្បាប់ដែលមានជាយូរហើយនោះបានបង្កើតជាវិធានដែលផ្អែកលើការប្រព្រឹត្ត ""ការពន្យារពេលដោយមិនសមហេតុផល" ដែលបានបង្កើតជាផលប្រយោជន៍សំខាន់ៗជាច្រើនសម្រាប់ជនជាប់ចោទ។ ជាឧទាហរណ៍ នៅសហរដ្ឋអាមេរិក វិធាន McNabb-Mallory ត្រូវបានបង្កើតឡើងនៅកំរិតសហព័ន្ធដែលចែងថា "ការពន្យារពេលដោយមិនសមហេតុផល" នៅក្នុងការកាត់ទោសធ្វើឲ្យការសារភាពទុកជាមោឃៈ ទោះការសារភាពនោះធ្វើដោយស្ម័គ្រចិត្តក្តី។ នេះបង្ហាញនូវទម្ងន់ដែលច្បាប់សហព័ន្ធដាក់ទៅលើការចែងដែលមិនអនុញ្ញាតឲ្យមានការពន្យារពេលមិនសមហេតុផល។

យង់ឃ្លងដូចដែលបានចោទប្រកាន់ និងសិទ្ធិរបស់ជនជាប់ឃុំ ដូចដែលខាងព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបានអះអាងថាការដោះលែងជនជាប់ឃុំរង់ចាំការជំនុំជម្រះនឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការនីតិវិធី និងខាងមេធាវីការពារក្ដីអះអាងថាមានការខូតខាតដល់សិទ្ធិរបស់កូនក្ដីខ្លួន ។

សារណានេះ មានបំណងចង់វិភាគ និងផ្ដល់ការស្ថាបនាសម្រាប់ច្បាប់សារធាតុ វិធាន និងនីតិវិធីដែលត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការឃុំខ្លួន កាំង ហ្គេច អ៊ាវ ដូចដែលបានផ្ដល់ជូននូវគំនិតទាំងស្រុងក្នុងសារណានេះស្រាប់។ គំនិតមួយចំនួនសម្រាប់ការពិចារណារបស់អង្គបុរេជំនុំជម្រះមាន (១) ការពោលអះអាងរបស់សារណានេះ ដោយ អ.វ.ត.ក. គឺជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា ដូច្នេះ តុលាការនេះមានភាពផ្សាភ្ជាប់គ្នាទៅនឹងយុត្តាធិការនៅក្នុងប្រព័ន្ធនេះ ដូចជាតុលាការយោធាក្រុងភ្នំពេញ។ (២) សេចក្ដីអះអាងដែលថាអង្គបុរេជំនុំជម្រះមានយុត្តាធិការដើម្បីពិនិត្យការឃុំខ្លួនរបស់ កាំង ហ្គេច អ៊ាវ នៅមុន អ.វ.ត.ក.។ (៣) ដោយសំអាងថាច្បាប់ដែលយកមកសំអាងក្នុងការចោទប្រកាន់ និងឃុំខ្លួនមុនការបង្កើតនៃ អ.វ.ត.ក. កាលពីពេលនោះ ត្រូវបានចាត់ទុកជាមោឃៈ ឬមិនអនុលោមទៅតាមកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ឬត្រូវបានអនុមត្តិឡើងក្នុងចេតនាឱ្យអនុវត្តបានជាមួយនឹងនីតិវិធីរឿងក្ដីនៅចំពោះមុខ អ.វ.ត.ក. និងមិនមានយុត្តាធិការអ្វីផ្សេងពីនេះ។ (៤) រយៈពេលអូសបន្លាយវែងនៃការឃុំខ្លួនមុន អ.វ.ត.ក. គឺមានភាពជ្រុលហួសប្រមាណ និងភាពត្រឹមត្រូវដែលតុលាការយោធាក្រុងភ្នំពេញបានអះអាងថាខ្លួនមានចេតនា "ធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវមួយ" គឺគ្មានមូលដ្ឋាន។ (៥) រយៈឃុំខ្លួនបណ្ដោះអាសន្នលើរូប កាំង ហ្គេច អ៊ាវ គឺមានភាពជ្រុលហួសប្រមាណ បើគិតតាមបទដ្ឋានអន្តរជាតិ និងមានការខូតខាតដល់សិទ្ធិរបស់ជនជាប់ឃុំដែលត្រូវបានការពារដោយកាតព្វកិច្ចទាំងអស់គ្នានៃរដ្ឋកម្ពុជា។ (៦) ដីការបង្គាប់ឱ្យឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ត្រូវបានបង្គាប់ឡើងដោយឈរលើមូលដ្ឋាននៃបទល្មើសដដែល ដោយផ្អែកលើច្បាប់ដដែលយកមកសំអាងក្នុងការបង្គាប់ឱ្យឃុំខ្លួនកាលពីលើកមុន និងបន្តឃុំខ្លួនរហូតផុតវេលាកំណត់ដែលអនុញ្ញាតិជាអប្បបរមានៃអាជ្ញាយុកាលរបស់វា។

សារណានេះសន្និដ្ឋានថាមានកត្តាពីរយ៉ាងដែលសមនឹងដោះលែង កាំង ហ្គេច អ៊ាវ រង់ចាំការជំនុំជម្រះ ។ (១)ចំនួននៃសេចក្ដីសម្រេចដែលមានការភាន់ច្រឡំស្ដីអំពីការអនុវត្តន៍ច្បាប់ប្រឆាំងនឹងរូបគាត់។ (២)

00154381

គាត់ត្រូវបានឃុំខ្លួនម្តងរួចទៅហើយ ដោយផ្អែកលើមូលដ្ឋាននៃបទឧក្រិដ្ឋដដែល ដែល សំអាងលើច្បាប់ដែលមានតម្កល់ទុកដដែល ដែលការឃុំខ្លួននេះបានផុតកំណត់វេលាដែលអនុញ្ញាតិជាអប្បបរមានៃអាជ្ញាយុកាលរបស់វា។ សារណានេះគ្មានចេតនាអ្វីក្នុងការតតាំងដើម្បីឲ្យមានការ ដោះលែងដោយសារតែកំហុសឆ្គងនីតិវិធីទេ ត្បិតអីគាត់យល់ថាទម្ងន់នៃការចោទប្រកាន់ប្រឆាំងនឹង កាំង ហ្គេច អ៊ាវ ក្នុងករណីនេះ មិនអាចធ្ងន់ជាងចំនួននៃកំហុសឆ្គងច្រើនដងផ្នែកច្បាប់ ដែលតុលាការយោធាក្រុងភ្នំពេញ និង អ.វ.ត.ក.បានប្រព្រឹត្តមកដល់ចំណុចនេះនោះទេ។ គាត់គ្រាន់តែចង់ផ្តល់ជាអនុសាសន៍ថា កាំង ហ្គេច អ៊ាវគួរត្រូវដោះលែងរង់ចាំការជំនុំជម្រះ និងឈរលើមូលដ្ឋាននៃកត្តាពីរយ៉ាងខាងដើម។ អង្គបុរេជំនុំជម្រះអាចដាក់លក្ខខណ្ឌក្នុងការដោះលែងនេះបាន ដូចជាការឃ្លាំមើលរយៈពេញ២៤ម៉ោង ឬអ្វីផ្សេងពីនេះ កិច្ចសន្យាជាលាយលក្ខណ៍អក្សរថានឹងមកបង្ហាញខ្លួននៅពេលជំនុំជម្រះ កិច្ចសន្យាជាលាយលក្ខណ៍អក្សរថាពិតជាមិនផ្លាស់ប្តូរអាស័យដ្ឋាន ។ល។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹងនៅតែត្រូវធ្វើការកំណត់អំពីមូលដ្ឋាននៃហេតុផលសម្រាប់ការឃុំខ្លួនដែលប្តឹងដោយសហព្រះរាជអាជ្ញា និងតម្កល់ទុកដដែលដោយសហចៅក្រមស៊ើបអង្កេត ដូចជាថាតើជនជាប់ឃុំអាចគេចខ្លួនដែរឬយ៉ាងណា ថាតើសាធារណៈទូទៅមានប្រតិកម្មយ៉ាងដូចម្តេច ប្រសិនបើគាត់គួរគេដោះលែង និងសកម្មភាពដែលជនជាប់ឃុំត្រូវទទួលខុសត្រូវធ្វើដើម្បីផ្លាស់ប្តូរភស្តុតាងប្រឆាំងរូបគាត់ ទាំងអស់នេះគឺស្ថិតនៅក្រៅវង្វង់នៃការវិភាគរបស់សារណានេះ ប៉ុន្តែវាអាចបញ្ចូលក្នុងការឆ្លើយទៅនឹងបញ្ហានៃការដោះលែងជនជាប់ឃុំបានខ្លះដែរ។

ម្ចាស់សារណាជឿជាក់ថា មិនចំពោះថាអង្គបុរេជំនុំជម្រះជ្រើសរើសយកមកប្រើនូវទឡ្ហីករណ៍ណាមួយខាងលើនោះទេ គឺខ្លួនបានដឹងអំពីបេសកកម្មប្រវត្តិសាស្ត្ររបស់ខ្លួនដែលមិនមែនត្រឹមតែចូលរួមក្នុងការវិនិច្ឆ័យទោសនៃសំនុំរឿងរបស់សមាជិកនៃរបស់កម្ពុជាប្រជាធិបតេយ្យដូចដែលបានកំណត់ទុកប៉ុណ្ណោះទេ ប៉ុន្តែអំពីផលត្រលប់ដែលបានមកពីសេចក្តីសម្រេចរបស់ខ្លួនដែលនឹងធ្វើទៅលើដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការក្នុងប្រទេសកម្ពុជាផងដែរ។ ក្នុងតំណាក់កាលនេះ អង្គបុរេជំនុំជម្រះមានឱកាសក្នុងការជួយដល់ការបញ្ចប់នូវវប្បធម៌និទ្ទណ្ឌភាព តាមរយៈការបញ្ចេញនូវសារមួយថាតុលាការនេះ ឬតុលាការណាមួយផ្សេងទៀតក្នុងប្រទេសកម្ពុជានឹងគ្រប់គ្រងដោយច្បាប់ មិនចំពោះថាមានមហិច្ឆតា និង របៀបវារៈនយោបាយដែលអាចនៅពីក្រោយខ្នងនៃការកាត់ទោសចំពោះបុគ្គលពិសេសៗទាំងនេះឬយ៉ាងណានោះឡើយ។

## កំណត់សម្គាល់

ម្ចាស់សារណា សូមសរសើរដោយឥតសង្ស័យចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងការជួយប្រើប្រាស់អំណាចរបស់ខ្លួន ឱ្យជាប្រយោជន៍ ដូចចែងក្នុងវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការប្រមូលសារណាសាធារណៈជន ពីបណ្តាអង្គការរដ្ឋាភិបាល និងសមាជិកសាធារណៈ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីបានពិចារណាលើការពិតមួយដែលថា វិធាន ៣៣ មិនបានផ្តល់នូវក្របខណ្ឌពេលវេលាជាក់លាក់ដែលត្រូវឱ្យធ្វើ និងដាក់សារណាជូននោះឡើយ ម្ល៉ោះហើយរឿងនេះគឺស្រេចលើចៅក្រមសម្រេចអំពីពេលវេលាកំណត់នេះ។ ដូច្នេះយើងសូមជូនជាអនុសាសន៍ថា រយៈកំណត់ ៣០ថ្ងៃ នាពេលបច្ចុប្បន្ននេះ គួរត្រូវពិចារណាឡើងវិញដើម្បីគោលបំណងក្នុងការប្រមូលសារណាបែបនេះ ទៅថ្ងៃអនាគត។ ហេតុផលមួយដែលយកមកសំអាងក្នុងការចង់ឱ្យមានការពិចារណាឡើងវិញនូវពេលវេលាកំណត់នេះ គឺថាអ្នកធ្វើសារណាមួយចំនួនប្រហែលជាអាចធ្វើមិនទាន់ទេ ដោយហេតុផលនៃក្របខណ្ឌនៃអង្គការផ្សេងៗ ឬដោយសារតែរចនាសម្ព័ន្ធនៃហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ឱ្យផ្សេងៗទៀត និងអាចដោយសារតែចំនួនម៉ោងដែលកំណត់ដែលពួកគេអាចបរិច្ចាកបានប្រចាំសប្តាហ៍ទៅលើកិច្ចការនេះ។ ប្រការនេះអាចនឹងមានការប៉ះពាល់ដល់គុណភាពនៃឯកសារដែលផ្ញើជូនទៅអង្គបុរេជំនុំជម្រះ ឬក៏អាចនឹងធ្វើប្រឆាំងទាំងស្រុងទៅនឹងចេតនាជាសក្តានុពលរបស់អ្នកដែលចង់ចូលរួមបង្កើតនូវសារណាបែបនេះ។ ដោយការគិតគូដល់ចំណុចនេះ ខ្លួនស្នើឱ្យបន្ថែមពេលវេលាដែលបានអនុញ្ញាតិនាពេលបច្ចុប្បន្នឱ្យបានពីរដងលើសនេះ។